# ចូរគោរពតាមផ្លាកសញ្ញា និងសញ្ញាសម្គាល់ផ្លូវរបស់ជប៉ុន(1)

| | | | |
|---|---|---|---|
|  | ទាំងមនុស្ស ទាំងយានយន្ត ត្រូវតែឈប់។ ហើយក៏មិនអនុញ្ញាតឱ្យបត់ស្តាំ និងបត់ឆ្វេងឡើយ។ |  | ត្រូវតែឈប់នៅកន្លែងដែលមានសញ្ញានេះ។ |
|  | ភ្លើងពណ៌ក្រហម ក៏ប៉ុន្តែអ្នកអាចបន្តដំណើរទៅតាមទិសដៅព្រួញបាន។ |  | |
|  | មិនអនុញ្ញាតឱ្យយានយន្តបើកបរទេ។<br>*យានយន្តរួមទាំងកង់ផងដែរ។ |  | អ្នកត្រូវតែបើកបរយឺតៗនៅកន្លែងដែលមានសញ្ញានេះ។<br>* ល្បឿនដែលបានណែនាំគឺ 10km/h ឬយឺតជាងនេះ ដែលជាល្បឿនអាចឈប់ភ្លាមៗបាន។ |
|  | មិនអនុញ្ញាតឱ្យរថយន្តផ្សេងទៀត ក្រៅពីទោចក្រយានបើកបរទេ។ |  | |
|  | រថយន្តដឹកទំនិញធំៗមិនអាចបើកបរបានទេ។ |  | អ្នកអាចបើកបរក្នុងល្បឿនត្រឹមតែតួលេខដែលបានបង្ហាញលើនេះប៉ុណ្ណោះ។ |
|  | នេះជាផ្លូវសម្រាប់រថយន្ត ហើយអ្នកថ្មើរជើង កង់ ទោចក្រយានមានម៉ូទ័រ ជាដើម មិនអាចបើកបរ ឬដើរតាមផ្លូវនេះបានទេ។ |  | |
|  | ផ្លូវនេះគឺសម្រាប់អ្នកថ្មើរជើង និងកង់តែប៉ុណ្ណោះ ហើយមិនអនុញ្ញាតឱ្យយានយន្តផ្សេងទៀតបើកបរទេ។ |  | នៅកន្លែងសម្រាប់អ្នកថ្មើរជើងឆ្លងផ្លូវ ពេលដែលមានអ្នកចង់ឆ្លង ត្រូវតែឈប់ ហើយផ្តល់អាទិភាពទៅអ្នកនោះឆ្លង។ |
|  | ផ្លូវនេះសម្រាប់តែអ្នកថ្មើរជើង ហើយមិនអនុញ្ញាតឱ្យយានយន្តបើកបរទេ។ |  | |



# ចូរគោរពតាមផ្លាកសញ្ញា និងសញ្ញាសម្គាល់ផ្លូវរបស់ជប៉ុន(2)

| | | | |
|---|---|---|---|
|  | នៅលើផ្លូវមួយទិស អ្នកអាចទៅបានតែតាមទិសនៃព្រួញប៉ុណ្ណោះ។ |  | យានយន្តអាចបើកបរតាមទិសដៅនៃព្រួញប៉ុណ្ណោះ។ |
|  | អ្នកមិនអាចធ្វើដំណើរទៅតាមទិសដែលមានសញ្ញានេះបានទេ។ |  | នៅចំណុចប្រសព្វគ្នា ត្រូវតែបើកបរតាមគន្លងដែលបានកំណត់ អាស្រ័យលើទិសដៅធ្វើដំណើររបស់អ្នក។ |
|  | មិនអាចបត់ត្រឡប់ក្រោយបានទេ។ |  | |
|  | |  | នេះគឺជាគន្លងផ្លូវសម្រាប់យានយន្តដែលត្រូវបានកំណត់ពិសេស។ |
|  | នៅពេលដែលវ៉ាយានយន្តនៅពីមុខ មិនត្រូវចេញហួសខ្សែបន្ទាត់ពណ៌លឿងទៅខាងស្តាំឡើយ។ |  | |
|  | |  | នៅខាងមុខនេះ មានផ្លូវរថភ្លើងឆ្លងកាត់។ |
|  | មិនអនុញ្ញាតឱ្យចតរថយន្ត និងឈប់មួយរយៈពេលទេ។ |  | មានសាលារៀននៅក្បែរនេះ ហើយមានក្មេងៗដើរច្រើន។ |
|  | មិនអាចចតបានទេ។ |  | នៅខាងមុខនេះ មានផ្លូវប្រសព្វគ្នា។ |

福岡県警察
Fukuoka Prefectural Police

# សូមគោរពច្បាប់ និងបើកបរប្រកបសុវត្ថិភាពនៅប្រទេសជប៉ុន(1)

## (1) បើកបរប្រកាន់ឆ្វេង



★ ប្រទេសជប៉ុន គេបើកបរប្រកាន់ឆ្វេង។ ចំពោះអ្នកដែលធ្លាប់បើកបរប្រកាន់ស្តាំនៅប្រទេសខ្លួន ពេលបត់នៅចំណុចប្រសព្វជាដើម អាចច្រឡំបើកបរលើគន្លងខាងស្តាំ ដូច្នេះសូមប្រយ័ត្ន។

★ ការបើកបរលើគន្លងខាងស្តាំ គឺអាចមានគ្រោះថ្នាក់ ហើយអាចជាការបំពានច្បាប់ចរាចរណ៍។

## (2) បើមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង សូមរាយការណ៍ទៅប៉ូលីស

★ ប្រសិនបើមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ត្រូវទូរស័ព្ទទៅប៉ូលិស (110) ទោះជាមិនមានអ្នករបួសក៏ដោយ។ ក្នុងករណីដែលមានអ្នករបួស ត្រូវជួយសង្គ្រោះបឋមអ្នករងគ្រោះ ហើយហៅរថយន្តសង្គ្រោះបន្ទាន់ (119) ព្រមទាំងទូរស័ព្ទទៅប៉ូលីស (110)។

★ ប្រសិនបើអ្នកមិនបានផ្តល់ជំនួយសង្គ្រោះបឋមដល់អ្នករងរបួស ឬមិនរាយការណ៍ពីគ្រោះថ្នាក់នេះទៅប៉ូលីសទេ អ្នកនឹងត្រូវទទួលរងការពិន័យយ៉ាងធ្ងន់ធ្ងរ និងទណ្ឌកម្មរដ្ឋបាលធ្ងន់ធ្ងរ ដូចជាការដកហូតប័ណ្ណបើកបររបស់អ្នកជាអាទិ៍។



## (3) ការហាមការបើកបរក្នុងស្ថានភាពស្រវឹង

★ ក្រោយពេលផឹកស្រា ដាច់ខាតមិនត្រូវបើកបរទេ។ ក្រៅពីការពិន័យធ្ងន់ធ្ងរ មានវិធានការរដ្ឋបាលដ៏តឹងរ៉ឹងដូចជាការដកហូតប័ណ្ណបើកបរផងដែរ។

★ កុំផ្តល់យានយន្តដល់អ្នកណាដែលអាចបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង។ លើសពីនេះ មិនត្រូវទាមទារ ឬស្នើសុំឱ្យអ្នកណាដែលបានផឹកស្រា បើកបរ ឬជិះជាមួយអ្នកបើកបរណាដែលស្រវឹងស្រា។ ការរំលោភច្បាប់ទាំងនេះ អាចបណ្តាលឱ្យមានការផាកពិន័យធ្ងន់ធ្ងរ។



ពេលនៅសល់កំសួលស្រា នៅថ្ងៃបន្ទាប់ ក៏មិនត្រូវបើកបរដែរ !

## (4) ឈប់នៅកន្លែងឆ្លងកាត់ផ្លូវដែក

★ នៅពេលឆ្លងកាត់ផ្លូវដែក ទោះបីជាមិនមានសំឡេងរោទិ៍ក៏ដោយ ក៏ត្រូវតែឈប់ ហើយពិនិត្យមើលថាតើមានរថភ្លើងមកដល់ឬទេ មុនពេលឆ្លងកាត់។



## (5) ឱ្យអាទិភាពទៅអ្នកថ្មើរជើង

★ នៅប្រទេសជប៉ុន អ្នកថ្មើរជើងមានអាទិភាពខ្ពស់ជាងគេ។ ប្រសិនបើឃើញអ្នកថ្មើរជើងចង់ឆ្លងកាត់ផ្លូវនៅកន្លែងឆ្លងកាត់ផ្លូវ ឬផ្លូវប្រសព្វ ត្រូវឈប់ ហើយផ្តល់សិទ្ធិឆ្លងកាត់ផ្លូវដល់អ្នកទាំងនោះ។



## (6) ត្រូវប្រយ័ត្នជាពិសេសនៅចំណុចប្រសព្វ

★ នៅចំណុចប្រសព្វ "(1) អ្នកថ្មើរជើងមានសិទ្ធិអាទិភាព" "(2) ពេលបត់ស្តាំ យានយន្តដែលបើកបរត្រង់ ឬបត់ឆ្វេងមានសិទ្ធិអាទិភាព"

★ ពេលមានអ្នកថ្មើរជើងកំពុងឆ្លង ឬហៀបនឹងឆ្លងផ្លូវនៅកន្លែងសម្រាប់អ្នកថ្មើរជើងឆ្លងកាត់ ត្រូវតែ "ឈប់"។




## (7) ហាមប្រើទូរស័ព្ទដៃ



★ ពេលកំពុងបើកបរយានយន្ត មិនត្រូវនិយាយទូរស័ព្ទដៃ ឬមើលអេក្រង់ទេ លើកលែងតែក្នុងករណីមានការបន្ទាន់។

## (8) យល់អត្ថន័យនៃផ្លាកសញ្ញាឱ្យត្រឹមត្រូវ

ប្រទេសជប៉ុនមានច្បាប់ចរាចរណ៍ និងផ្លាកសញ្ញាខុសពីប្រទេសកំណើតរបស់អ្នក។




★ នៅកន្លែងដែលមានផ្លាកសញ្ញានេះ ត្រូវតែឈប់ ហើយពិនិត្យឆ្វេងស្តាំមើលសុវត្ថិភាព។

**ប័ណ្ណបើកបរមានអំឡុងពេលសុពលភាព ដូច្នេះកុំភ្លេចបន្តប័ណ្ណបើកបរ។**

福 岡 県 警 察

Fukuoka Prefectural Police

# សូមគោរពច្បាប់ និងបើកបរប្រកបសុវត្ថិភាពនៅប្រទេសជប៉ុន(2)

## (9) ចូរយល់ដឹងឱ្យច្បាស់អំពីប្រភេទយានយន្តដែលអ្នកអាចបើកបរបាន

★ ប្រភេទយានយន្តដែលអ្នកអាចបើកបរអាចខុសពីយានយន្តដែលមានប័ណ្ណបើកបរនៅក្នុងប្រទេសកំណើតរបស់អ្នក។
★ សូមពិនិត្យមើលយានយន្តដែលអ្នកអាចបើកបរបានមុននឹងបើកបរ។

| | |
|---|---|
| ធុនធម្មតា | ចំនួនអ្នកជិះអតិបរមា 10នាក់<br>ទម្ងន់រថយន្តសរុប ក្រោម 3,500kg<br>ទម្ងន់ផ្ទុកអតិបរមា ក្រោម 2,000kg |
| ធុនប្រហែលមធ្យម | ចំនួនអ្នកជិះអតិបរមា 10នាក់<br>ទម្ងន់រថយន្តសរុប ក្រោម 7,500kg<br>ទម្ងន់ផ្ទុកអតិបរមា ក្រោម 4,500kg |
| ធុនមធ្យម | ចំនួនអ្នកជិះអតិបរមា 29នាក់<br>ទម្ងន់រថយន្តសរុប ក្រោម 11,000kg<br>ទម្ងន់ផ្ទុកអតិបរមា ក្រោម 6,500kg |
| ធុនធំ | ចំនួនអ្នកជិះអតិបរមា ពី30នាក់ឡើងទៅ<br>ទម្ងន់រថយន្តសរុប 11,000kgឡើងទៅ<br>ទម្ងន់ផ្ទុកអតិបរមា 6,500kgឡើងទៅ |
| ទោចក្រយានយន្តធុនធ | ចំនួនអ្នកជិះអតិបរមា 2 នាក់<br>ទំហំម៉ាស៊ីន លើស 400cc ឬកម្លាំងលើស 20kW |
| ទោចក្រយានយន្តធម្មតា | ចំនួនអ្នកជិះអតិបរមា 2 នាក់<br>ទំហំម៉ាស៊ីន ត្រឹម400cc ឬកម្លាំងត្រឹម 20kW |
| យានយន្តអូសទាញ | រ៉ឺម៉កដែលមានទម្ងន់សរុបលើស 750kg |

※ស្តីពីបរិមាណផ្ទុក ឬចំនួនអ្នកជិះអតិបរមា សូមបញ្ជាក់មើលនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីយានយន្តមុននឹងបើកបរ។

※ជាគោលការណ៍ ក្នុងអំឡុងពេលឆ្នាំ (សម្រាប់ផ្លូវល្បឿនលឿនគឺ3ឆ្នាំ) បន្ទាប់ពីបានប័ណ្ណបើកបរ មិនអាចជិះ2នាក់បានទេ ។









★ស្តីពីការបើកបរឡានក្រុងនិងតាក់ស៊ី

- ដើម្បីបើកបរឡានក្រុង ឬតាក់ស៊ី (ដឹកមនុស្សដោយយកថ្លៃជិះ) ត្រូវតែមាន "ប័ណ្ណបើកបរប្រភេទទី២"។
- អ្នកចាំបាច់មាន "ប័ណ្ណបើកបរប្រភេទទី២" អាស្រ័យលើប្រភេទរថយន្តដែលអ្នកនឹងបើកបរ។
- លើសពីនេះ ប្រសិនបើការងាររបស់អ្នកជាអ្នកដឹកជញ្ជូនមនុស្ស ក្រៅពីការមានប័ណ្ណបើកបរប្រភេទទី២ អ្នកក៏ត្រូវមានការអនុញ្ញាតពីមន្ទីរដឹកជញ្ជូន ជាអាទិ៍ បន្ថែមទៀត។




## (10) ចូរពិនិត្យមើលទំហំទំនិញដែលអាចផ្ទុកបាន និងរបៀបផ្ទុក។




★ចាំបាច់មានការអនុញ្ញាត

**មុខក្រោយ**
ករណីដែលទំនិញដែលផ្ទុកលយចេញលើស 1/10 នៃប្រវែងតួរថយន្តពីខាងមុខ ឬខាងក្រោយ

**ឆ្វេងស្តាំ**
ករណីដែលទំនិញដែលផ្ទុកបានលយចេញពីខាងឆ្វេង ឬខាងស្តាំ លើស 1/10 នៃទទឹងរថយន្ត

**ប្រវែង**
ករណីដែលប្រវែងនៃទំនិញដែលផ្ទុក មានលើសប្រវែងតួរថយន្ត 2/10

**ទទឹង**
ករណីដែលទទឹងនៃទំនិញដែលផ្ទុកវែងលើសទទឹងនៃតួរថយន្ត 2/10

**កំពស់**
ករណីដែលមានកំពស់លើស 3.8m (2.5m សម្រាប់រថយន្តធុនស្រាល មានកង់បួន ឬរថយន្តកង់បី) ដកនឹងកំពស់កន្លែងផ្ទុកទំនិញនៃរថយន្ត

★ ពេលផ្ទុកទំនិញលើឡានដឹកទំនិញ មានការកម្រិតអំពីទំហំ ទម្ងន់ និងវិធីផ្ទុក។

★ ប្រសិនបើទំនិញមិនអាចបែងចែកបាន ហើយលើសទម្ងន់ ឬទំហំ ឬវិធីផ្ទុកដែលត្រូវបានកំណត់ អ្នកបើកបររថយន្តដែលផ្ទុកទំនិញនោះត្រូវសុំការអនុញ្ញាតពីប្រធានមន្ទីរនគរបាលដែលមានសមត្ថកិច្ចនៅកន្លែងចេញដំណើរ។



**មានការពិន័យចំពោះការរំលោភច្បាប់ចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍។**

福 岡 県 警 察

Fukuoka Prefectural Police